Australian Government

Job Services Australia
people • skills • jobs

# The Harvest Trail

## គម្រោងផ្តួចផ្តើមការងារចម្ការ (Harvest Trail initiative) អាចជួយលោកអ្នករកការងារជាពលករប្រមូលកសិផល នៅតំបន់ជនបទ និងតាមតំបន់នានាក្នុងប្រទេសអូស្ត្រាលី។

កិច្ចការ Harvest មានជូនពេញមួយឆ្នាំ នៅពេលដែលអ្នកធ្វើការងារបេះផ្លែឈើ និងកាត់បន្លែតាមតំបន់មានចំនួនមិនគ្រប់គ្រាន់។

ទោះបីលោកអ្នកមានកម្រិតសិក្សា អាយុ ឬប្រវត្តិការងារអ្វីក៏ដោយ ក៏ការងារប្រមូលកសិផលផ្តល់ឱកាសដល់លោកអ្នកដើម្បី៖

- ធ្វើដំណើរផង និងធ្វើការងារផងនៅជុំវិញប្រទេសអូស្ត្រាលី
- ជួបមនុស្សម្នាមកពីប្រទេសនានាលើពិភពលោក
- ធ្វើការងារច្រើនប្រភេទ
- ភាគច្រើនមានការងារធ្វើ ស្ទើរពេញមួយឆ្នាំៗ។

លោកអ្នកក៏អាចជ្រើសរើសតំបន់ពិសេសណាមួយសម្រាប់កិច្ចការនេះដែរ។

## សេវាជាតិផ្តល់ព័ត៌មានអំពីការងារប្រមូលកសិផល (National Harvest Labour Information Service [NHLIS])

NHLIS ផ្តល់ព័ត៌មានយ៉ាងទូលំទូលាយ និងថ្មីៗទាន់សភាពការណ៍ អំពីការងារប្រមូលកសិផលដែលទំនេរ និងឱកាសការងារ តាមរយៈគេហទំព័ររបស់ Harvest Trail: **harvesttrail.gov.au**។

NHLIS ក៏ផលិតនិងចែកចាយនូវ**ការណែនាំទាក់ទងនឹងការប្រមូលកសិផលជាតិ (National Harvest Guide)** ដែលជាកូនសៀវភៅមានផ្ទុកព័ត៌មានអំពីឱកាសការងារប្រមូលផល លក្ខខណ្ឌការងារ ការដឹកជញ្ជូន និងការស្នាក់នៅពាសពេញក្នុងប្រទេសអូស្ត្រាលី។ ការណែនាំនេះចែកជូន **ដោយឥតគិតថ្លៃ** និងអាចរកមើលបានតាមអ៊ីនធើរណិតក្នុងគេហទំព័រ Harvest Trail។ កូនសៀវភៅណែនាំនេះត្រូវបានធ្វើឲ្យទាន់បច្ចុប្បន្នភាពយ៉ាងតិចក៏ ១ខែម្តង ហើយមានព័ត៌មានលម្អិតអំពីការប្រមូលកសិផល សម្រាប់តំបន់ប្រមូលផលនីមួយៗ ហើយការណែនាំនេះមានចែកជូនតាមរយៈ៖

- ស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia)
- ក្រុមឧស្សាហកម្មនៅតំបន់ប្រមូលផល
- Centrelink
- ស្ថាប័នអប់រំពាក់ព័ន្ធ
- ចំណត caravan
- ផ្ទះសំណាក់ទេសចរពនេចរ (backpacker hostels)
- មណ្ឌលព័ត៌មានរដ្ឋាភិបាលតាមតំបន់
- ការិយាល័យទេសចរណ៍
- ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត

NHLIS មានទំនាក់ទំនងជាមួយស្ថាប័នផ្តល់សេវាការងារប្រមូលកសិផល (Harvest Labour Service) ស្ថាប័នផ្តល់ Job Services Australia អ្នកដាំដំណាំ/បន្លែ សមាគមអ្នកដាំដំណាំ និងទីភ្នាក់ងារជ្រើសរើសបុគ្គលិកជាច្រើន។

NHLIS ក៏សហការជាមួយរដ្ឋាភិបាលតាមរដ្ឋ និងរដ្ឋាភិបាលដែនដីផង ដើម្បីពង្រីកឱកាសការងារប្រមូលកសិផល ដល់អ្នកស្វែងរកការងារធ្វើ និងនិយោជក។

## Harvest Labour Service

ស្ថាប័នផ្តល់សេវា Harvest Labour Service

- ជួយផ្តល់ឱវាទ និងព័ត៌មានជាប្រចាំ អំពីការងារប្រមូលកសិផលតាមរដូវកាលតាមតំបន់នានាក្នុងប្រទេស។
- ផ្តល់ព័ត៌មានអំពីកន្លែងស្នាក់នៅ របៀបទៅធ្វើការ ប្រាក់ឈ្នួល និងលក្ខខណ្ឌការងារផ្សេងៗ ក៏ដូចជាព័ត៌មានអំពីលក្ខខណ្ឌការងារប្រមូលកសិផល។
- ពង្រីកឱកាសការងារប្រមូលកសិផល ជាមួយអ្នកផ្តល់សេវាការងារផ្សេងទៀត និងក្នុងកន្លែងដែលមានអ្នកដំណើរពីបរទេសមកទស្សនា ដូចជា ផ្ទះសំណាក់ទេសចរពនេចរជាដើម។
- ជួយដល់អ្នកដាំដុះ និងតម្រូវការពលកម្មរបស់ពួកគេ ក្នុងអំឡុងពេលប្រមូលកសិផល។
- ត្រួតពិនិត្យមើលអ្នកស្វែងរកការងារធ្វើ ដើម្បីធានាថា អ្នកទាំងនោះមានសិទ្ធិធ្វើការក្នុងប្រទេសអូស្ត្រាលី និងស័ក្តិសមសម្រាប់និយោជក។
- ភ្ជាប់ទំនាក់ទំនងរបស់លោកអ្នកជាមួយនិយោជក។
- ផ្តល់ជំនួយបន្ទាន់ដល់សមាគមអ្នកដាំដុះ របស់និយោជក នៅពេលនិយោជកប្រឈមមុខនឹងកង្វះខាតអ្នកធ្វើការចម្ការក្នុងតំបន់របស់ខ្លួន។

## តើអ្នកណាអាចចូលរួមបាន?

ជនគ្រប់រូប ដែលមានសិទ្ធិស្របច្បាប់ក្នុងការធ្វើការងារក្នុងប្រទេសអូស្ត្រាលី មានសិទ្ធិចូលរួមក្នុងគម្រោងផ្តួចផ្តើមនេះ ទោះជាអ្នកនោះទទួលបាន ឬមិនទទួលបានប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូលក៏ដោយ។ អ្នកទាំងនោះរួមទាំង ប្រជាជនដែលមកទេសចរនៅប្រទេសអូស្ត្រាលី ហើយកាន់ទិដ្ឋាការអនុញ្ញាតត្រឹមត្រូវឲ្យធ្វើការងារ។

## របៀបដាក់ពាក្យសុំធ្វើការ

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ក្នុងការដាក់ពាក្យសុំចូលធ្វើការជាអ្នកប្រមូលកសិផលនោះ៖

- សូមទូរស័ព្ទទៅសេវាផ្តល់ព័ត៌មានអំពី National Harvest Labour តាមរយៈលេខ **1800 062 332** ដើម្បីឲ្យគេភ្ជាប់លោកអ្នកជាមួយស្ថាប័នផ្តល់សេវាក្នុងតំបន់ដែលលោកអ្នកចាប់អារម្មណ៍។
- សូមបើកមើលគេហទំព័ររបស់ Harvest Trail: **harvesttrail.gov.au**
- សូមទូរស័ព្ទ ឬជួបជាមួយស្ថាប័នផ្តល់សេវាការងារប្រមូលកសិផលដែលនៅជិតលោកអ្នក

11FS09446JSA/khmer

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

## ចំពោះព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅ National Harvest Labour Information Service តាមរយៈលេខ 1800 062 332 ឬ បើកមើលគេហទំព័រ harvesttrail.gov.au ។**